# ការបដិសេធភស្តុតាង៖ ករណីការថតសម្លេងតាមទូរស័ព្ទ

បទអត្ថាធិប្បាយលើសាលក្រម សំណុំរឿង ៣៣៦/២០០៥ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០០៥ និងលេខ ៤៦៣/២០០៥ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥ របស់តុលាការកំពូលប្រទេស អេស្ប៉ាញ (ផ្នែកព្រហ្មទណ្ឌ)

ដោយលោកចៅក្រម Michael BOHLANDER[23] ក្នុងទស្សនាវដ្តី ច្បាប់ព្រហ្មទណ្ឌ (Journal of Criminal Law) ភាគ ៧០ (៣) ឆ្នាំ ២០០៦

**បកប្រែដោយបណ្ឌិត មាស បូរ៉ា ដោយមានការអនុញ្ញាតពីលោកចៅក្រម Michael BOHLANDER**

នៅក្នុងសំណុំរឿងទាំងពីរនេះ តុលាការបានពិចារណានូវដីកាអនុញ្ញាតឲ្យថតសម្លេងទូរស័ព្ទចេញដោយចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿងទាក់ទិននឹងការចោទប្រកាន់អំពីបទល្មើសថ្នាំញៀនធ្ងន់ធ្ងរ។ ក្នុងនីតិវិធីមួយនៃដំណើរការនៃនីតិវិធីចំនួនហេរ៉ូអ៊ីន ១៦ គីឡូក្រាម ត្រូវបានជួញដូរដែលជាចំនួនដ៏ច្រើនចរាចរក្នុងទីផ្សារ។ ក្នុងករណីទាំងពីរនេះ ភស្តុតាងចោទប្រកាន់មួយចំនួនភ្ជាប់ជនត្រូវចោទនឹងបទល្មើសជាចម្បងបានមកពី ការថតសម្លេងឆ្លងឆ្លើយតាមទូរស័ព្ទផ្អែកតាមដីកាអនុញ្ញាត។ តុលាការវិនិច្ឆ័យក្នុងរឿងទាំងពីរ បានប្រើប្រាស់ភស្តុតាងទាំងនេះដើម្បីកាត់ទោស និងដាក់ពន្ធនាគាររយៈពេលយូរ។ ជនល្មើសបានប្តឹងសារទុក្ខទៅតុលាការកំពូល ដោយអះអាងថា ដីកាបំពានសិទ្ធិជីវិតឯកជនដែលជាលទ្ធផលការដាក់ទោសនេះបំពានគោលការណ៍សន្មត់ថាមិនទាន់មានទោស (presumption of innocence) ដោយសារតុលាការផ្អែកលើភស្តុតាងដែលមិនអាចទទួលយកបាន(inadmissible evidence) ហើយប្រសិនបើគ្មានភស្តុតាងនេះវានឹងមិនមានការចោទប្រកាន់ទេ (no case to answer)។ តុលាការកំពូលបានសម្រេចលុបចោលការផ្តន្ទាទោសទាំងពីរ ដោយគ្មានតម្រូវឲ្យមានការកាត់សេចក្តីជាថ្មី៖ ដីកាមិនមានភាពជាក់លាក់ និងហាក់ទំនងជាគ្រាន់តែសម្រាប់ប្រថាប់ត្រាដល់ប្រតិបត្តិការរបស់ប៉ូលីស។ ក្នុងសំណុំរឿងលេខ ៤៦៣/២០០៥ តុលាការ អះអាងក្នុងចំណុចលេខ ៤ ជាផ្នែកនៃការវាយតម្លៃអង្គច្បាប់នៃសំណុំរឿងថា៖ *ជាការអនុវត្ត ផ្អែកតាមចរិតការិយាធិបតេយ្យដីកានេះគ្រាន់តែជា ការប្រថាប់ត្រាលើសំណុំរឿងប៉ូលីស ដោយគ្រាន់តែសរសេរប្រាប់ថា (អនុវត្តទៅ!)*។

[23] លោកចៅក្រម Michael BOHLANDER ជាសហចៅក្រមស៊ើបអង្កេតនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ទោះបីជាទទួលស្គាល់យ៉ាងជាក់លាក់ថា ប៉ូលីសបានប្រតិបត្តិការងារប្រកបដោយវិជ្ជាជីវៈ និងសុទ្ធចិត្តក៏ដោយ ក៏ប៉ុន្តែក្នុងការរិះគន់ដល់សហការីជាតុលាការក្នុងអង្គរបស់ខ្លួនចៅក្រមតុលាការកំពូលបានអះអាងថា កិច្ចនោះមិនមែនជាសកម្មភាពស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតទេ។ តុលាការកំពូលប្រើពាក្យជាការមិនគោរព/ប្រមាថ (disgrace ful) និងអះអាងនូវកង្វះភាពសកម្មដ៏អាក្រក់ (lamentable lack of rigour) ក្នុងសំណុំរឿងមួយ ដែលចៅក្រមម្នាក់អសកម្មបំផុត។

## យោបល់

វាជាការពិចារណាដ៏ចម្លែកមួយស្ដីពី ច្បាប់របស់យើង ប្រសិនបើបុគ្គលម្នាក់បានទទួលស្គាល់ការចូលរួមក្នុងការនាំចូលខុសច្បាប់នូវគ្រឿងញៀនហេរ៉ូអ៊ីនក្នុងចំនួនច្រើន ប្រសិនបើពិរុទ្ធភាពត្រូវបានបដិសេធ ផ្អែកតាមមូលដ្ឋានថា សិទ្ធិជីវិតឯកជនរបស់គាត់ត្រូវបានបំពារបំពាន។

សេចក្ដីថ្លែងនេះ ដោយចៅក្រម Lord Nolan ក្នុងសុំរឿងក្នុងសំណុំរឿង *R v Khan* [1996] 1 WLR 162 ត្រង់ទំព័រ ១៧៥ ហាក់តំណាងនូវជំហរទូទៅ ក្នុងចំណោមចៅក្រមព្រហ្មទណ្ឌរបស់អង់គ្លេសពាក់ព័ន្ធនឹងសំណួរថាតើភស្តុតាងទទួលបានតាមមធ្យោបាយមិនសមស្រប ឬមិនស្របច្បាប់ គួរត្រូវបានទទួលយក ឬបដិសេធនាពេលសវនាការ...។

វិធីសាស្ត្រនេះ(ឲ្យរួចខ្លួន) នាំឲ្យមានភាពភ័យខ្លាចរបស់ពលរដ្ឋជាច្រើនព្រមទាំងមេធាវីក្នុងចំណោមប្រជាជន ដោយសារមានអារម្មណ៍ថា ឧក្រិដ្ឋជននឹងមានសេរីភាព ដោយសារមន្ត្រីបានធ្វេសប្រហែស (constable has blundered)។ នេះប្រសិនបើប្រើប្រាស់នូវសេចក្ដីថ្លែងការណ៍ដ៏ពេញនិយមលើកឡើងដោយចៅក្រម Cardozo ក្នុងឆ្នាំ ១៩៦២ ក្នុងសំណុំរឿង *People v Defore* 242 NY 13 ក្នុងទំព័រ ២១ (...ប្រជាជនស្រដៀងនេះភាគច្រើន នឹងសម្ដែងនូវសេចក្ដីប្រាថ្នាយ៉ាងខ្លាំង ដើម្បីការពារនូវសិទ្ធិរបស់ពួកគេនាពេលដែលពួកគេខ្លួនឯងកំពុងទទួលរងនូវផលវិបាក នៃការកាត់ទោសផ្អែកតាមភស្តុតាងប្រភេទនេះ)។ អារម្មណ៍ព្រួយថា ឧក្រិដ្ឋជនអាចរួចខ្លួនវាមានពិតប្រាកដជាពិសេសក្នុងករណីបទល្មើសធ្ងន់ធ្ងរ ដូចជារំលោភសេពសន្ថវៈ ឬមនុស្សឃាត។ ក្នុងរឿងក្ដី *Leon* តុលាការកំពូលសហរដ្ឋអាមេរិកអះអាងថា វិធានបដិសេធភស្តុតាង (exclusionary rule) ចែងក្នុងវិសោធនកម្មទី៤ នឹងមិនអនុវត្តចំពោះករណីភស្តុតាងទទួលបានដោយសមហេតុផល និងជាសត្យានុម័តផ្អែកលើដីកាឆែកឆេរ ដែលក្រោយមកដីកានេះត្រូវបានមោឃៈភាពទេ (468 US at 922, 104 SCt at 3420)។ ក្នុងរឿងក្ដី Moore 956 F2d843 សាលាឧទ្ធរណ៍អាមេរិកCircuit ទី៨ បានពន្យល់ថា តម្លៃខ្ពស់សង្គមនៃវិធានបដិសេធ

នាំឲ្យឧក្រិដ្ឋជនមានសេរីភាព ដោយសារមន្ត្រីបានធ្វេសប្រហែស។ ចៅក្រម Cardozo បានថ្លែងទាមទារមិនឲ្យអនុវត្តវិធាន ចំពោះស្ថានភាពដែលមន្ត្រីបានធ្វើការងារដោយហ្មត់ចត់។ ដូចនេះដរាបណាប៉ូលីស ឬរដ្ឋអាជ្ញាធ្វើការងារដោយសុទ្ធចិត្តកំហុសបន្ទាប់មក ឬទង្វើខុសច្បាប់ ដែលអាចកើតមានដោយមន្ត្រីតុលាការក្នុងការផ្តល់នូវដីកាឆែកឆេរ ឬដីកាស្រដៀងគ្នាជ្រៀតជ្រែកដល់សិទ្ធិឯកជននោះ វាមិនមែនជាវិធានទេ ដែលភស្តុតាងនឹងត្រូវបដិសេធដោយតុលាការ។ ជាការពិត ការលើកលែងដោយមូលហេតុសុទ្ធចិត្ត (good faith exception) គឺទទួលយកបានក្នុងទម្រង់ចំបង ប្រសិនបើវិធានបដិសេធជាវិធីសាស្ត្រដាក់ពិន័យ ។ ដូចនេះ វាមិនមានអត្ថន័យទេ ដែលដាក់ពិន័យលើប៉ូលីសខណៈដែលពួកគេមិនបានប្រព្រឹត្តកំហុស។ ក៏ប៉ុន្តែបញ្ហាអាចត្រូវបានមើលឃើញខុសគ្នាបន្តិចពីជ្រុងផ្សេងៗ ដោយសារថា សកម្មភាពកាត់ទោសទាំងអស់ចេញមកពីអំណាចរដ្ឋហើយរដ្ឋមិនមានសិទ្ធិលើកសំអាងសុទ្ធចិត្តភាព នៅពេលដែលរដ្ឋបំពានសិទ្ធិជីវិតឯកជនរបស់ពលរដ្ឋខ្លួនឡើយ។ នេះដោយសាររដ្ឋមានកាតព្វកិច្ច គោរពសិទ្ធិប្រជាពលរដ្ឋក្នុងលក្ខណៈជាការទទួលខុសត្រូវតឹងរឹង (strict liability)។ គេត្រូវទទួលស្គាល់ថា ការអះអាងនេះមិនបានឆ្លើយតបនឹងសំណួរបន្ទាប់ថា តើអ្វីទៅជាផលវិបាកអាចកើតមានបន្ទាប់ពីមានការរំលោភសិទ្ធិ និងថាតើការបដិសេធភស្តុតាង វាជាវិធីសាស្ត្រល្អបំផុត ក្នុងគ្រប់កាលៈទេសៈដែរឬទេ?។

វិធីសាស្ត្រនេះ (បដិសេធភស្តុតាង) មិនមានក្នុងប្រព័ន្ធច្បាប់ទាំងអស់ទេ។ ជាពិសេសប្រទេសដែលធ្លាប់ឆ្លងកាត់រយៈពេលនៃរបបផ្តាច់ការនិយម ឬការបង្ក្រាបគាំទ្រដោយរដ្ឋ នឹងមានភាពទោមនស្ស ចំពោះភាពមិនអាចបំពានបាននៃសិទ្ធិស៊ីវិលឬសិទ្ធិចម្បង។ ប្រទេសអេស្ប៉ាញក្រោយពីងើបចេញពីការគ្រប់គ្រងដោយលោក ហ្វ្រង់ ស៊ីស្កូ ហ្វ្រង់កូ (Francisco Franco) នៃប្រទេសទាំងឡាយដែលដាក់តម្លៃសង្គមខ្ពស់ លើសិទ្ធិស៊ីវិល សូម្បីតម្រូវឲ្យមានការដោះលែងឧក្រិដ្ឋជនឲ្យរួចខ្លួនក្តី។ ករណីទាំងពីរសម្រេចដោយតុលាការកំពូល ផ្អែកជាស៊ីសង្វាក់តាមយុត្តិសាស្ត្ររបស់តុលាការធម្មនុញ្ញអេស្ប៉ាញ បានបង្ហាញនូវផលវិបាកនៃវិធីសាស្ត្រនេះ។ វិធីសាស្ត្រនេះ ទំនងទទួលឥទ្ធិពលខ្លាំងពីយុត្តិសាស្ត្រតុលាការធម្មនុញ្ញសហព័ន្ធអាឡឺម៉ង់ ក៏ប៉ុន្តែតុលាការអេស្ប៉ាញហាក់មានជំហរ រ៉ាឌីកាល់(radical) ជាងក្នុងការអនុវត្តគោលការណ៍នេះ។ ជំហរប្រកាន់យកដោយតុលាការកំពូលរបស់អេស្ប៉ាញ ទទួលបាននូវការសរសើរក្នុងពេលដែលការការពារសិទ្ធិចំបងតាមផ្លូវតុលាការមិនមានតម្លៃខ្ពស់ក្នុងសង្គមដោយសារភាពចាំបាច់នៃសង្គ្រាមប្រឆាំងភេរវកម្ម ដែលអំណាចប្រតិបត្តិមាន អំណាចទូលំទូលាយ។ ការសរសើរនេះ មានជា

ពិសេសដោយពិចារណាលើអង្គហេតុថា អេស្ប៉ាញ បានទទួលរងនូវការវាយប្រហារភេរវកម្មធំក្រោយ ថ្ងៃទី១១ ខែកញ្ញា ហើយសាលក្រមត្រូវបានចេញក្រោយពីមានព្រឹត្តិការណ៍(ភេរវកម្ម) ក្នុងទីក្រុងម៉ាទ្រីត។

ខ្លឹមសារសង្ខេបនៃការយល់ឃើញរបស់តុលាការក្នុងរឿងទាំងនេះ បានបង្ហាញថា ការខកខានត្រួតពិនិត្យតាមផ្លូវតុលាការ ប្រកបដោយប្រសិទ្ធភាពលើវិធានការកម្រិតសិទ្ធិបុគ្គលមានអត្ថន័យក្នុងធម្មនុញ្ញ ហើយការខកខាននេះត្រូវតែនាំឲ្យមាននូវមោឃកម្មនៃវិធានការ។ ធាតុផ្សំចំបង នៃការត្រួតពិនិត្យ គឺការពិនិត្យថាតើវិធានការ វាមានភាពចាំបាច់ ហើយការចាត់ចែងភស្តុតាង ត្រូវតែផ្អែកតាមវិធានទាំងនោះ ឬយ៉ាងណា។ ធាតុផ្សំទាំងនេះនៅបន្តមានរហូតក្នុងអំឡុងពេលទាំងស្រុងនៃវិធានការនោះ។ វាមិនគ្រាន់តែយោងឡើងវិញនៅក្នុងដីកាដែលមានហេតុផលគ្រប់គ្រាន់ ដើម្បីអនុម័តនូវវិធានការ ឬមិនគ្រប់គ្រាន់ទេក្នុងការយោងដល់ឯកសាររបស់ប៉ូលីស (ទោះបីការយោងដល់ឯកសារតុលាការកម្រិតត្រឹមការអនុញ្ញាត) ក៏ប៉ុន្តែមូលដ្ឋាននៃការវាយតម្លៃនេះត្រូវតែចែងយ៉ាងច្បាស់លាស់ និងជាក់លាក់ក្នុងសំអាងហេតុនៃចៅក្រម។

គោលការណ៍ សមាមាត្រនៃច្បាប់រដ្ឋធម្មនុញ្ញតម្រូវឲ្យចៅក្រមពិចារណាដោយហ្មត់ចត់ថាតើការចោទប្រកាន់តម្រូវនូវវិធានការជ្រៀតជ្រែក ដូចនោះ ដូចជាការថតសំឡេងសន្ទនាតាមទូរស័ព្ទព្រមទាំងថាតើ វិធីសាស្ត្រនៃការស៊ើបអង្កេតដទៃទៀត មិនអាចធ្វើទៅបានឬ?។ ការពិចារណាត្រូវបានពន្យល់ផងដែរនូវមូលហេតុនៃការចេញដីកា។ វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា តុលាការកំពូលកំណត់នូវភាពជាក់លាក់យ៉ាងច្បាស់រវាងអង្គហេតុដែលបានចោទ និងមូលដ្ឋានភស្តុតាងសម្រាប់ការចោទប្រកាន់។ ទោះបីមានការបរិយាយលម្អិតនូវសកម្មភាពដែលបានចោទលើជនសង្ស័យ វានឹងមិនទាន់គ្រប់គ្រាន់ទេ ប្រសិនបើតុលាការមិនបានកំណត់ជាក់លាក់នូវការយល់ឃើញថា មានការសង្ស័យសមស្របប្រឆាំងនឹងជនសង្ស័យ ផ្អែកតាមភស្តុតាងផ្តល់ក្នុងពាក្យសុំរបស់ប៉ូលីស។ តុលាការបាននិយាយយ៉ាងច្បាស់ថា ការកំណត់ចោទប្រកាន់មិនអាចជាយុត្តិកម្មសម្រាប់វាយតម្លៃថាមានសំណុំរឿងគ្រប់គ្រាន់ប្រឆាំងនឹងជនសង្ស័យថាគាត់បានប្រព្រឹត្ត នូវសកម្មភាពចោទនោះទេ។ ការធ្វើដូចនេះ នាំឲ្យធ្លាក់ចូលក្នុងអន្ទាក់នៃអំណះអំណាងដដែលៗ (circular argument)។ ជាមួយនឹងការប្រើប្រាស់ពាក្យដាច់ខាតបន្តិចចៅក្រមតុលាការកំពូលបានយោងជាក់លាក់ដល់ការប្រើពាក្យញុះញង់ (magic trigger words) ដូចជា "*ក្រុមមានការចាត់តាំង*" "*ជួញដូរគ្រឿងញៀនក្នុងទម្រង់ធំ*" "*បញ្ជីថ្កោលទោសពី*

*មុន" "ទំនាក់ទំនង"* ជាដើម នៅក្នុងពាក្យសុំ និងបទបញ្ជាអនុញ្ញាតជាធាតុផ្សំដែលធ្វើឲ្យពាក្យសុំត្រូវបានចាត់ថាមានហេតុផល។ ដោយគ្មានការពិចារណាហ្មត់ចត់នូវភស្តុតាងផ្តល់ជូន ដោយប៉ូលីស វាមានន័យថា វាជាការផ្ទេរអំណាចតុលាការពិតមួយទៅដល់ប៉ូលីស។

តុលាការកំពូលសង្កត់ធ្ងន់ថា ការពិចារណាណាមួយលើពាក្យសុំ សម្រាប់វិធានការជ្រៀតជ្រែក ត្រូវតែផ្អែក តាមទស្សនៈជាមុន (*ex-ante* view) នៃភស្តុតាងផ្តល់ជូន។ ដើម្បីផ្តល់យុត្តិកម្មដល់វិធានការ ដែលអនុវត្តប្រតិសកម្ម ក្រោយពីភាពជោគជ័យនៃការស៊ើបអង្កេត វាមានន័យថា ជាការផ្អាកការអនុវត្តដ៏មានប្រសិទ្ធភាព នូវមាត្រា ១១(១) នៃច្បាប់ Ley Organica Del Poder Judicial ច្បាប់ស្តីពីអង្គតុលាការ ដែលបានចែងថា ភស្តុតាងណាមួយ ទទួលបានដោយបំពានសិទ្ធិសេរីភាពចំបង ទោះបីដោយផ្ទាល់ ឬប្រយោលក្តី នឹងមិនទទួលយកឡើយ។ ប្រសិនមិនត្រូវបានលុបបំបាត់ទេ វានឹងកម្រិតយ៉ាងធ្ងន់ធ្ងរនូវការការពារក្រោមមាត្រា២៤ នៃច្បាប់ធម្មនុញ្ញ អេស្ប៉ាញ ដែលធានានូវសិទ្ធិត្រួតពិនិត្យ ដោយតុលាការមានប្រសិទ្ធភាព ទៅលើទង្វើរបស់រដ្ឋ។

វាតម្រូវឲ្យមានការចងចាំថា ការពិនិត្យជាមុន ជាការទាមទារដោយច្បាប់រដ្ឋធម្មនុញ្ញ ដែលថា សកម្មភាពណាមួយរបស់រដ្ឋ ហើយជាពិសេសវិធានការបំពារបំពានត្រូវតែអនុលោមតាមគោលការណ៍សមាមាត្រ (តុលាការអេស្ប៉ាញប្រើនិយមន័យសមាមាត្រ ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការធម្មនុញ្ញសហព័ន្ធអាឡឺម៉ង់)៖ វិធានការទាមទារ៖ ទី១. សមត្ថភាពនៃការបង្កើតនូវផលវិបាកដែលចង់បាន។ ទី២. វាចាំបាច់ ដោយសារថា មិនមានវិធីដែលបំពារបំពានតិចតួចអាចធ្វើបានដែលបង្កើតបានផលវិបាកដូចគ្នា និងទី ៣ បើទោះបី ចំណុចទី១ និង ទី២ ត្រូវបានបំពេញការបំពារបំពាន ដោយមានបំណងត្រូវតែសមាមាត្រនឹងផលប្រយោជន៍ទទួលបានពីវិធានការដែលពេលខ្លះអាចត្រូវបានចាត់ថា *"សមាមាត្រក្នុងន័យចង្អៀត"*។ ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការធម្មនុញ្ញ អេស្ប៉ាញ លក្ខខណ្ឌទាំងនេះត្រូវតែមានក្នុងគ្រប់ដំណាក់កាលនៃវិធានការ ហើយនេះត្រូវតែបានពិនិត្យ នៅពេលពិចារណា ការដាក់ចេញវិធានការអនុវត្តថ្មី។

តុលាការដដែលបានប្រើប្រាស់នូវទ្រឹស្តី ការបំពុលជាក់ច្បាស់(unequivocal contamination) ហើយតុលាការបានពិនិត្យថា តើមានភស្តុតាងសេសសល់ទទួលបានផ្អែកតាមភស្តុតាងទទួលបានតាមរយៈការថតសម្លេងទូរស័ព្ទ និងថាតើការដាក់ទោសអាចរក្សាទុកដោយគ្មានភស្តុតាងប្រភេទក្រោយនេះទេ។ ការអនុវត្តតាមទ្រឹស្តីនេះតុលាការកំពូលបានប្រកាសថា ការដាក់ទោសនេះធ្វើឡើងដោយផ្អែកទាំងស្រុងលើភស្តុតាងបំពុល ហើយបាន

បដិសេធការដាក់ទោស ព្រមទាំងបានបញ្ជាឲ្យដោះលែងជនត្រូវចោទទាំងអស់។ តុលាការមិនបានពិចារណាជាក់លាក់ថាវាចាំបាច់ក្នុងការពិភាក្សាហេតុផលផ្សេងៗទៀត មានក្នុងពាក្យបណ្តឹងឧទ្ធរណ៍ ដែលអះអាងដល់តម្លៃខ្ពស់ដល់ការការពារសិទ្ធិចម្បងក្នុងទ្រឹស្តីច្បាប់អេស្ប៉ាញទេ។ វាជារឿងថ្មីក្នុងការប្រកាន់យកនូវជំហរដ៏ជាក់លាក់ ឲ្យប្រយោជន៍ដល់សិទ្ធិ និងសេរីភាពចម្បង ផ្ទុយនឹងតម្លៃដទៃទៀតដែលត្រូវបានបង្ហាញព្រមទាំងការធ្វើតុល្យភាពនូវតម្លៃកំពុងកើតមានក្នុងនយោបាយសម័យទំនើប។ បុគ្គលអាចមានការងឿងឆ្ងល់ថាតើរហូតដល់ពេលណាដែលប្រព័ន្ធតុលាការអេស្ប៉ាញនឹងអាចឈរជើងទល់នឹងសំពាធនៃការភ័យខ្លាច នៃការបំពានអំណាចនេះ។

<u>សេចក្តីសម្រេចទាំងស្រុងអាចរកមាននៅ គេហទំព័ររបស់តុលាការ www.poderjudicial.es.</u>